# ក្រុមការពារក្ដីឱ្យអ្នកស្រី អ៊ឹម ចែម នៅ អ.វ.ត.ក

## DEFENCE TEAM FOR MS. IM CHAEM AT THE ECCC

លោក ប៊ិត សៀងលីម និងលោក Wayne JORDASH, QC

ទីក្រុងភ្នំពេញ/ទីក្រុងឡុងដ៍

ធ្វើនៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-June-2018, 09:13
CMS/CFO: Sann Rada

**ជូនចំពោះ : អង្គបុរេជំនុំជម្រះ**

**កម្មវត្ថុ : ចម្លើយតបទៅនឹងការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) (D308/3/1/15)**

ជូនចំពោះអង្គចៅក្រមជាទីគោរព

យើងខ្ញុំជាសហមេធាវីការពារក្ដីឱ្យអ្នកស្រី អ៊ឹម ចែម តទៅនេះសូមធ្វើការឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ។

ការឆ្លើយតបនេះ គឺធ្វើឡើងដោយភាពចាំបាច់ ដោយសារតែសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងនូវបញ្ហាមួយដែលអង្គបុរេជំនុំជម្រះមិនបានស្នើឱ្យមានការដាក់សេចក្ដីសន្និដ្ឋានដូច្នេះ នៅក្នុងពាក្យអញ្ជើញរបស់ខ្លួន ពោលគឺអំពីថាតើសវនាការគួរត្រូវធ្វើជាសាធារណៈដែរឬយ៉ាងណានោះឡើយ ។ ការពិត អង្គបុរេជំនុំជម្រះបានស្នើសុំភាគីឱ្យបរិយាយ*ត្រឹមតែ*បញ្ជាក់ពីការចូលរួមរបស់ពួកគេក្នុងកាលបរិច្ឆេទដែលបានគ្រោងទុក និងពីពេលវេលាដែលបានបែងចែកឱ្យសម្រាប់ធ្វើអំណះអំណាងផ្ទាល់មាត់តែប៉ុណ្ណោះ ។ ដើម្បីការពារសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបាននូវការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ វាមានសារសំខាន់ណាស់ដែលយើងខ្ញុំត្រូវធ្វើការឆ្លើយតបនឹងសំណើបន្ថែមនេះ ។

យើងខ្ញុំសូមស្នើដល់អង្គបុរេជំនុំជម្រះ មេត្តាបដិសេធលើសំណើសុំធ្វើសវនាការជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

អនុលោមតាមវិធាន ៧៧(៦) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិក្នុងការស្នើសុំឱ្យធ្វើសវនាការសាធារណៈនៅចំពោះមុខអង្គបុរេជំនុំជម្រះបាន ។ ទោះបីជាយ៉ាងណាក្តី វិធានផ្ទៃក្នុង ៧៧(៦) មិនបានផ្តល់ឱ្យមានការធ្វើសវនាការជាសាធារណៈដោយស្វ័យប្រវត្តិនោះទេ នៅពេលដែលសំណុំរឿងក្តីអាចត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ប៉ុន្តែករណីនេះ *គ្រាន់តែ*ជាការផ្តល់នូវលទ្ធភាពមួយស្ថិតក្រោមកាលៈទេសៈពិសេសប៉ុណ្ណោះ ។ ដូចដែលធ្លាប់បានសម្រេចកាលពីពេលកន្លងទៅដូច្នោះដែរ វាជារឿងសំខាន់ ដែលរាល់សេចក្តីសម្រេចទាក់ទងនឹងការផ្សព្វផ្សាយជាសាធារណៈនូវដំណើរការនីតិវិធីទាំងឡាយនាដំណាក់កាលនេះ គប្បីត្រូវធ្វើការថ្លឹងថ្លែងឱ្យបានហ្មត់ចត់លើផលប្រយោជន៍យុត្តិធម៌ និង "ដោយពិចារណាទៅលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត ដែលមានដូចជា ការរក្សាសិទ្ធិ និងផលប្រយោជន៍របស់ភាគី" ដែលអាចគាំទ្រឱ្យមាននូវដំណើរការនីតិវិធី*អសាធារណៈ* ដើម្បីរក្សាការសម្ងាត់នៃព័ត៌មានដ៏រសើប ព្រមទាំងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទាំងមូល[1] ។ ប៉ុន្តែ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនបានផ្តល់ការបង្ហាញឱ្យឃើញនោះទេថាតើការជ្រើសយកវិធីសាស្ត្របែបនេះ ធ្វើឡើង "ដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពាររបស់តុលាការ" ដូចម្តេចខ្លះ[2] ។

ផ្នែកសំខាន់នៃបញ្ហាមួយចំនួន ដែលនឹងត្រូវលើកយកមកដោះស្រាយនៅសវនាការក្នុងដំណាក់កាលនេះ ត្រូវបានចាត់ទុកជាការសម្ងាត់ ។ ទាំងនេះ បូករួមទាំងទឡ្ហីករណ៍នានាក្នុងបណ្តឹងឧទ្ធរណ៍ទាក់ទិននឹង

---

[1] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស*, ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខ **D138** ត្រង់កថាខណ្ឌ ១២ ។ *សូមមើលផងដែរ*, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ ធ្វើនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D309/2** ត្រង់កថាខណ្ឌ ១២-១៨; សេចក្តីណែនាំឱ្យអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (សេចក្តីណែនាំឱ្យអនុវត្តនៅ អវតក/០០៤/២០០៩/វិ.លើកទី ២) មាត្រា ១.២ [សង្កត់ធ្ងន់នៅក្នុងគោលការណ៍ណែនាំឱ្យអនុវត្តនេះថាវា "គឺជាតម្រូវការទាមទារឱ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើការនីតិវិធីរបស់តុលាការដែលមិនបើកចំហរដល់សាធារណជន [ជាមួយនឹង] តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ"] ។

[2] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) ដែលបានអនុម័តឱ្យប្រើប្រាស់នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ (វិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥), វិធាន៧៧(៦) ។

វិសាលភាពនៃការចោទប្រកាន់ដែលអាចអនុញ្ញាតឱ្យធ្វើទៅបាន[3] ភស្តុតាងពាក់ព័ន្ធនឹងបទចោទមួយចំនួនដែលអ្នកស្រី អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់[4] ការវិភាគលើអង្គហេតុនានាផ្អែកលើបទចោទស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[5] ភស្តុតាងដែលរកឃើញដោយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការចោទប្រកាន់អំពីតួនាទីរបស់អ្នកស្រី អ៊ឹម ចែម នៅភូមិភាគនិរតី[6] និងមានបញ្ហាជាច្រើនផ្សេងទៀតដែលនៅតែរសើប ហើយបង្កើតបានជាភាពសម្ងាត់ និងក្តីកង្វល់ផ្នែកសន្តិសុខ ។

ដូចយើងខ្ញុំបានគូសបញ្ជាក់ជូនអង្គបុរេជំនុំជម្រះរួចហើយនៅក្នុងសារណាមុនៗ ថាព័ត៌មានភាគច្រើនឬទាំងអស់គួរតែរក្សាជាការសម្ងាត់ បើគ្មានហេតុផលសមរម្យអ្វីបញ្ជាក់ថា អវត្តមាននៃការជំរុញឱ្យមានការបង្ហាញព័ត៌មានដូច្នេះ ជាការរំលោភបំពានដ៏ធ្ងន់ធ្ងរលើផលប្រយោជន៍សាធារណៈទេនោះ ។ អ្វីដែលសំខាន់បំផុតគឺថា កម្រិតនៃការដាក់បង្ហាញព័ត៌មានបច្ចុប្បន្ននេះ មិនទំនងជារំលោភលើផលប្រយោជន៍សាធារណៈ

---

[3] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៧, ឯកសារលេខ **D308/3/1/1** ត្រង់កថាខណ្ឌ១១-១២ ។ *សូមមើលផងដែរ*, ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** ត្រង់កថាខណ្ឌ២៤៤-២៤៥ *មើលធៀបគ្នានឹង*, [កោសលុប] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** ត្រង់កថាខណ្ឌ២៤៤-២៤៥ ។

[4] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៧, ឯកសារលេខ **D308/3/1/1** ត្រង់កថាខណ្ឌ២៣-៣៧ ។ *សូមមើលផងដែរ*, ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** ត្រង់កថាខណ្ឌ២៤៦-២៨០ *មើលធៀបគ្នានឹង*, [កោសលុប] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** ត្រង់កថាខណ្ឌ២៤៦-២៨០ ។

[5] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៧, ឯកសារលេខ **D308/3/1/1** ត្រង់កថាខណ្ឌ៣៨-៥៧ ។ *សូមមើលផងដែរ*, ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** ត្រង់កថាខណ្ឌ២៨៧-២៨៨ និងកថាខណ្ឌ ៣០២ *មើលធៀបគ្នានឹង*, [កោសលុប] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** ត្រង់កថាខណ្ឌ២៨៧-២៨៨ និងកថាខណ្ឌ ៣០២ ។

[6] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ធ្វើនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៧, ឯកសារលេខ **D308/3/1/1** ត្រង់កថាខណ្ឌ៥៨-៨១ ។ *សូមមើលផងដែរ*, ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** ត្រង់កថាខណ្ឌ១៤៣-១៥០ *មើលធៀបគ្នានឹង*, [កោសលុប] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារលេខ **D308/3** នៅកថាខណ្ឌ១៤៣-១៥០ ត្រង់ជើងទំព័រលេខ ២៦១-២៦២, ២៦៤-២៦៦, ២៧០-២៧៥, ២៧៧-២៨១ ។

អ្វីឡើយ សម្រាប់ការទទួលបាននូវសំអាងហេតុតុលាការដ៏សំខាន់នៅក្នុងសំណុំរឿង០០៤/១[7] ។ ដូចបានតវ៉ានៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីការកោសលុបដីកាដំណោះស្រាយដូច្នោះដែរ លក្ខណៈដាច់ខាតនៃការលើកលែងបទចោទប្រកាន់នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ គឺតម្រូវឱ្យប្រកាន់ខ្ជាប់នូវវិធីសាស្ត្ររក្សាការសម្ងាត់យ៉ាងតឹងរ៉ឹង[8] ។ លក្ខណៈ និងទំហំនៃការផ្សព្វផ្សាយដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើឡើង រួមបញ្ចូលទាំងការរែកញែកពីការអនុវត្ត *ហួសពីដែនអំណាច* ពីកម្មវត្ថុ និងគោលបំណងនៃដីកាដំណោះស្រាយ[9] គឺជាហានិភ័យបង្កឱ្យមានផលប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតថាគ្មានទោស និងសិទ្ធិមានជីវិតឯកជនរបស់អ្នកស្រី អ៊ឹម ចែម[10] ។ ហេតុផលទាំងនេះ មិនមែនជារឿងតូចតាចនោះទេ ពីព្រោះបញ្ហាទាំងនេះនឹងត្រូវធ្វើការដាក់បញ្ចាំងនៅក្នុងសាលសវនាការ ជាជាងការធ្វើសារណាជាលាយលក្ខណ៍អក្សរ និងការផ្តល់សំអាងហេតុតាមផ្លូវតុលាការ ។

ទោះក្នុងករណីណាក៏ដោយ សំណួរចោទលើបញ្ហាកម្រិតសមរម្យនៃការបង្ហាញជាសាធារណៈនូវនីតិវិធីនៃសំណុំរឿង០០៤/១ គឺជាបញ្ហាដែលកំពុងស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញរបស់តុលាការ (បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ*

---

[7] ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ធ្វើនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧, ឯកសារលេខ **D309/2/1/3** ត្រង់កថាខណ្ឌ ២៨-៣៨ ។

[8] ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ធ្វើនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧, ឯកសារលេខ **D309/2/1/3** ត្រង់កថាខណ្ឌ ៤០-៤៧ ។

[9] ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ធ្វើនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧, ឯកសារលេខ **D309/2/1/3** ត្រង់កថាខណ្ឌ ៦២-៦៧ ។

[10] ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ធ្វើនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧, ឯកសារលេខ **D309/2/1/3** ត្រង់កថាខណ្ឌ ៤៨-៦១ ។

*(សម្អាងហេតុ)* (D309/2/1/2)) ។ បញ្ហានេះអាចត្រូវសម្រេចនៅបន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់មុនពេលឈានដល់សវនាការលើអង្គសេចក្តី ។ នីតិវិធីនេះ នឹងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអន្តរជាតិមានឱកាសធ្វើបទបង្ហាញសំខាន់ៗ ហើយភាគីទាំងអស់ ព្រមទាំងអង្គបុរេជំនុំជម្រះក៏នឹងមានឱកាសសមស្របមួយដើម្បីស្វែងយល់ពីកង្វល់នានា និងរិះរកអំណះអំណាងជំទាស់ ។

យោងតាមសំអាងហេតុខាងលើ យើងខ្ញុំសូមស្នើអង្គបុរេជំនុំជម្រះមេត្តាសម្រេចច្រានចោលនូវសំណើសុំធ្វើសវនាការជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងស្នើសុំឱ្យធ្វើសវនាការតាមការគ្រោងទុកជាអសាធារណៈ ដោយអនុលោមតាមវិធាន ៧៧(៥) នៃវិធានផ្ទៃក្នុង ។ ក្រុមការពារក្តីក៏សូមរក្សាសិទ្ធិផងដែរក្នុងការដាក់សេចក្តីសន្និដ្ឋានផ្ទាល់មាត់លើបញ្ហានៃការសុំធ្វើសវនាការសាធារណៈនេះ នៅពេលមានសវនាការ ។

ដោយសេចក្តីគោរពរាប់អានអំពីយើងខ្ញុំ៕

**សហមេធាវីការពារក្តីឱ្យអ្នកស្រី អ៊ឹម ចែម**

[ ] [ ]

BIT Seanglim — Wayne JORDASH, QC